## ជំពូកទី១

## ហេតុអ្វីបង្កាន់ដៃនោះបាត់?

«ប្រសិនបើអង្គចៅក្រម ពិចារណាឃើញថាការស៊ើបអង្កេតមិនពេញលេញ ឬថាមានវិសាលភាពសម្រាប់ការស៊ើបអង្កេតបន្ថែមទៀត ចៅក្រមអាចបដិសេធ របាយការណ៍ចុងក្រោយរបស់ប៉ូលីសដែលបានបិទចោលសំណុំរឿងនេះ!»

នាងតាមដានស្ដាប់ទាំងសោមនស្ស។ អ្វីមួយជាក្ដីសង្ឃឹមកំពុងរំលេចឡើង ប៉ុន្តែស្នូរដកដង្ហើមធំនៃអ្នកដែលកំពុងនិយាយ បានបង្អាក់ភាពសុទិដ្ឋិនិយមរបស់នាង។

«តែធីតា! »

អ្នកនិយាយបញ្ឈប់ត្រឹមណោះ ហាក់បីដូចជាកំពុងរកនឹកពាក្យសមរម្យមកពន្យល់នាង។ អ្នកនោះទំនងជាដឹងថា បទសន្ទនា និងយោបល់គេសំខាន់ដល់នាងកម្រិតណា បានជាគេគិតហ្មត់ចត់ជានិច្ចមុនពេលវាចាមួយម៉ាត់ៗ។

«តែអីទៅ?!»

នាងសួរខ្សឹបៗ តែពាក្យខ្លីៗនេះជាសញ្ញាថានាងមិនអាចរង់ចាំយូរជាងនេះបានទេ។ សំឡេងនៃអ្នកដកដង្ហើមធំអម្បាញ់មិញ និយាយឡើងវិញ៖

«បើរកមិនបានភស្តុតាងថ្មី ច្បាស់ៗខ្លឹមៗ ចៅក្រមក៏ពិបាកសើរើសំណុំរឿងនេះឡើងវិញដែរ!»

ភ្នែករបស់នាងលម្អទៅដោយភាពវៃឆ្លាតនិងសេចក្ដីក្លាហាន ប៉ុន្តែនាងក៏ត្រូវព្រមទទួលយកនូវភាពស្មុគស្មាញដែលជាការពិតចំពោះមុខដែរ។

ជាអ្នកកាសែតម្នាក់ ដ្បិតតែធីតាមិនចេះច្បាប់ជ្រៅជ្រះដូចអ្នកដែលនាងកំពុងតែមកប្រឹក្សាជាមួយម្នាក់នេះ តែនាងក៏អាចផ្ដោតពិចារណាលើការពន្យល់នេះបានយ៉ាងល្អ។ ចំណុចនីមួយៗនៃបញ្ហាកំពុងត្រូវបានវាយតម្លៃ និងវិភាគស្រួចស្រាល់ក្នុងខួរក្បាល។ ធីតាវាចាតបតិចៗអំពីការសម្រេចចិត្តរបស់ខ្លួន៖

«អ៊ីចឹងហើយបានជាខ្ញុំសម្រេចចិត្តព្យួរការងារ ចេញទៅរតនគីរីឆាប់ៗនេះ!»

គូសន្ទនាដកដង្ហើមធំលាន់មកម្ដងទៀត។ នាងដឹងថាគេនេះបារម្ភ និងមិនគាំទ្រលើគំនិតចុងក្រោយរបស់នាង គ្រាន់តែគេមិនហ៊ានបង្អាក់។

ស្រស់ស្រីរវ៉ែក្មេកគិតចុះឡើងមុនពេលនិយាយពន្យល់ស្រាលជាងមុនទៅទៀត៖

«ខ្ញុំមានរឿងមួយចំនួនដែលអាចគាំទ្រគំនិតខ្លួនឯងថា នេះជាការសម្រេចចិត្តត្រឹមត្រូវ!»

«អ្វីទៅ? ឬធីតាមានភស្តុតាងថា លោកពូមិនបានស្លាប់ដោយឧប្បត្តិហេតុ?!»

នាងក្រោកចេញពីតុហើយរហ័សរហួនទៅលើកយកប្រអប់ក្រដាស់មួយមកដល់។ ជាប្រភេទប្រអប់ផ្ញើតាមប៉ៃ្រសណីយ៍។ ដោយដាក់វាមកលើតុចំពីមុខដៃគូពិភាក្សា នាងចាប់បើកវាចេញសន្សឹមៗ។

ក្រៅពីម៉ាស៊ីនថតមួយ វាមានក្រដាសស្នាមមួយសំណុំទៀត។

«ពូខ្ញុំដូចដឹងខ្លួនថា គាត់កំពុងមានគ្រោះថ្នាក់!»

នាងអង្គុយចុះមកវិញ ខណៈអ្នកកំពុងអង្គុយតទល់រវ៉ែក្មេកចុះឡើងសម្លឹងទូទាំងប្រអប់បញ្ញើ។

ធីតានិយាយបន្តទាំងរើការមេរ៉ាហុចមកឱ្យដៃគូ៖

«គាត់ផ្ញើប្រអប់មួយនេះមក ៨ថ្ងៃមុនពេលធ្លាក់ស្លាប់!»

«ក្នុងនេះមានរូបអីខ្លះ? ហេតុអីគាត់មិនផ្ញើជា file ចាំបាច់អីដាក់ទាំងម៉ាស៊ីនមក?!»

មិនរង់ចាំចម្លើយ គេចុចបើកហើយពិនិត្យមើលអ្វីៗដែលស្តុកទុកក្នុងម៉ាស៊ីនថត។ ក្រៅពីសម្រស់សួនផ្កា និងភូមិដ្ឋានឈើដ៏ស្រស់ប្រណីត អ្នករុករកមិនបានឃើញអ្វីគួរឱ្យកត់សម្គាល់ទៀតសោះ។

គេងើបមុខសម្លឹងមកនាងវិញទាំងដៃសងខាងនៅកាន់ឧបករណ៍មិនទាន់បិទ។

នៅចំពោះមុខ ធីតាជាអ្នកកាសែតស្រីវ័យក្មេងដែលទទួលបានការចាប់អារម្មណ៍ខ្លាំងក្នុងចំណោមវ័យស្របាលនាងអំពីសមត្ថភាពទេពកោសល្យវិជ្ជាជីវៈលេចធ្លោកាលនៅសាលា។

«ធីតាឯងទើបត្រឡប់មកភ្នំពេញហើយពិបាកដៃរទម្រាំទទួលបានការងារពេញម៉ោង! មិនទាន់រួចសាកល្បងបីខែផងដឹង? គុណសម្បត្តិរបស់ធីតាលើអាជីពមិនទាន់មានជាដុំកំភួនទេនៅផ្ទង់ធ្វើការសិនទៅឬម៉េច?!»

គេឱ្យយោបល់ទាំងដឹងហើយថា នាងសម្រេចចិត្តព្យួរការងារថ្មោងថ្មីមួយនេះចោល ព្រោះតែហេតុផលផ្សេង ដែលធំជាការស្រលាញ់អាជីពរបស់នាងទៅទៀតនោះ គឺការសង្ស័យជុំវិញមរណភាពពូនាង ។

«ខ្ញុំត្រូវដឹងការពិត បានចិត្តអាចស្ងប់មកផ្តោតធ្វើការបាន!»

នាងនិយាយទាំងទឹកមុខស្មើតែក្រៀមស្រពោន។

ឃើញដូច្នោះ អ្នកកំពុងតែសួរក៏បោះពាក្យបន្ថែមមកទៀត៖

«ម៉ាស៊ីនថតនេះបញ្ជាក់អីបាន?!»

ធីតាដកដង្ហើមវែងៗហើយនិយាយមួយៗបកស្រាយ៖

«នៅពេលទទួលបានរបស់ខ្ញុំក៏សួរទៅគាត់ចំពោះសំណួរនេះ! គាត់ឆ្លើយថា ទុកឱ្យល្អសូម្បីមួយសន្លឹកក៏កុំលុបចោល!»

អ្នកសួរឱនសម្លឹងម្ដងទៀត ហើយសារជាថ្មីគេចុចរូបថតទាំងអស់នៅក្នុងនោះពិនិត្យឡើងវិញម្ដងមួយៗ។

«ធីតាដែលរកពួកជំនាញខាង Steganography ពិនិត្យរូបអស់នេះដែរ?!»

«គ្មាននរណាម្នាក់ដឹងរឿងនេះ និងបានពាល់កាមេរ៉ានេះនៅឡើយ ក្រៅពីខ្ញុំនិងពូខ្ញុំ! បងឯងដឹងឥឡូវនេះ ជាអ្នកទីបីហើយ!»

«អ៊ីចឹងវាលែងស្ងាត់ហើយ!»

គេនោះនិយាយទាំងសើចទោះដឹងជាស្រេចហើយថា ធីតាមិនមានអារម្មណ៍ស្ងប់សម្រាប់មកលេងសើចជាមួយខ្លួនក៏ដោយ។  គេសួរមួយៗទាំងហុចម៉ាស៊ីនសងនាង៖

«ហេតុអីបានជាធីតាគិតថា របស់បញ្ញើទាំងនេះបញ្ជាក់ពីការដឹងមុនរបស់គាត់?»

«ក្រៅពីហ្នឹងគាត់បានផ្ទេរលុយកាក់និងកម្មសិទ្ធិដីខ្លះនៅជនបទ នៅសមុទ្រ និងនៅខ្ពង់រាប មកឱ្យខ្ញុំជាក្មួយ!»

គួសន្ធនាងើបមុខសម្លឹងនាង ហើយរេគ្រាប់ភ្នែកវាងវៃទៅរកបណ្ដាសំណុំឯកសារផ្ទេរមរតកមួយចំនួនដែលនាងហុចមកឱ្យពិនិត្យបន្ត។ អ្នកពិនិត្យមិនទាន់ថាអ្វីនៅឡើយ ក៏ប៉ុន្តែធីតាពន្យល់បន្ថែមទាំងស្រងូត៖

«ឃើញរបស់អស់នេះ ខ្ញុំចាប់ផ្ដើមមានអារម្មណ៍អាក្រក់!»

«អត់អីទេ! តោះគិតម្ដងមួយៗ!»

«បានរបស់ដល់ដៃប្រហែលជា៦ថ្ងៃ ខ្ញុំបានដំណឹងថាគាត់ស្លាប់! និយាយទៅបើទោះជាមុនគាត់មានរឿងខ្ញុំមិនបានដាក់ពាក្យវិលមកធ្វើការនៅស្រុកខ្មែរនេះក៏ដោយ ក៏ខ្ញុំត្រូវតែមកវិញដែរ»

«ចុះហេតុអីមកភ្លាមមិនគិតសិក្សារឿងនេះភ្លាមទុកដល់តែពីរខែទៅហើយ?!»

ធីតាស្រងូតៈ

«ដំបូងខ្ញុំរកអ្វីជាហេតុផលជំរុញខ្លួនឯងមិនបានសោះ មិនដឹងថា បើនឹងឡើងទៅរតនគិរីភ្លាមក៏មិនដឹងបានអីនិយាយឬសំអាង តែ....ម្សិលមិញខ្ញុំរកឃើញរបស់នេះ!»

គូសន្ទនាចងចិញ្ចើម....គេដៀងភ្នែកសម្លឹងកូនសៀវភៅដែលនាងហុចមកឱ្យ។ គេមិនទទួលនៅឡើយរហូតដល់នាងតឿនៈ

«អក្សរទាំងអស់ជារបស់ពូខ្ញុំ! សៀវភៅនេះនៅក្នុងប្រអប់សម្ងាត់ដែលខាងធនាគារហៅខ្ញុំទៅយកជាមួយលុយកាក់គ្រឿងអលង្ការខ្លះ!»

អ្នកទទួលចាប់ផ្តើមបើកអាន។

«ធីតា! នាឡិកានេះ ប៉ាឯងទិញជូនមកពូពាក់ កាលពូទើបប្រលងចប់វិទ្យាល័យ! ពូរក្សាទុកវា ជាការដឹងគុណដល់ទឹកចិត្តបងថ្លៃ! ចំណែកខ្សែកមាសបន្តោងរូបនាគ១នេះម្តាយឯងទិញចងដៃពេលពូពេលរៀបការជាមួយម៉ាក់ឧត្តម! កាលហ្នឹងគ្រួសារយើងមានជីវភាពធម្មតា ពូមិនចេះរកអីចេះតែចាយលុយនិងខំរៀន ហើយចង់បានប្រពន្ធជាកូនគេអ្នកមានទៀត! តែមានបងស្រីនិងបងថ្លៃតាមទំនុកបម្រុងរកទាំងប្រាក់បណ្ណាការទាំងមាសមកចងដៃប្អូន! ជាការតបស្នង លុយកាក់អស់នេះ ពូបានបម្រុងទុកឱ្យឯងទុកទំនុកបម្រុងខ្លួនតទៅមុខ ព្រោះឯងកំព្រាឪពុកម្តាយ! ពូម្នាក់នេះ ក៏មិនដឹងបាននៅមើលឯងធំ ដល់ពេលណាដែរ! កាលឯងទូរស័ព្ទមកពូមិនហ៊ាននិយាយដោយសារតែខ្លាចឯងខូចចិត្តរៀនមិនចូល»

គេងក់ក្បាលតិចៗពេលកំពុងអាន ហាក់ដូចជាផ្តើមទទួលស្គាល់ពីសម្តីមុនៗរបស់នាង ដែលបានធ្វើការសន្និដ្ឋានថា លោកមាមិនបានស្លាប់ដោយឧប្បត្តិហេតុ។

ធីតានិយាយគ្របពីលើអារម្មណ៍គូសន្ទនាៈ

«ខ្ញុំនៅមិនសុខទេ បានជាមករកបងទាំងព្រឹក!»

«មិនអីទេ!» បុរសនេះនិយាយខ្លីៗក្រោមការតាមដានពិនិត្យដោយក្តីសង្ស័យរបស់នាង។

គេងើបមុខហើយហុចសៀវភៅមកវិញដ្បិតតែមានទំព័រច្រើនទៀតគេនៅមិនទាន់បានអាន។ មនុស្សនេះមិនចង់ដឹងរឿងឯកជនអ្នកដទៃច្រើនទេ នាងដឹងចរិតគេ។

«បងអាចជួយឯងរក steganography មកម្នាក់ប្រសិនធីតាថាចង់បាន!»

«សំខាន់តើគេលាក់ការណ៍ឱ្យយើងបានល្អដែរ?!»

«បងគិតថាគេរកស៊ីខាងណោះ គេមិនផ្តេសផ្តាសទេ!!»

នាងងក់ក្បាលឃឹតៗទាំងពិចារណាតាមលំដាប់លំដោយផង។

«មុនពេលបានដំណឹងពីបង ធីតានៅភ្នំពេញធ្វើការបន្តសិនក៏បាន!»

«ខ្ញុំដាក់ពាក្យឈប់ហើយបង!!» នាងឆ្លើយដោយមិនរារែក ពេល SMS នាងលោតមកជាសារខ្លី

«ខ្ញុំជួបធីតាបានស្អែកម៉ោង៣រសៀល! ពីអធិការភារម្យ!»។

នារីដៀងភ្នែកសម្លឹងបន្តិចហើយងាកមកនិយាយជាមួយអ្នកនៅពីមុខខ្លួនៈ

«ខ្ញុំត្រូវតែទៅដល់ផ្ទះនោះសិន! មុននឹងក្រោយគង់តែស៊ើបដដែល ពន្យារពេលនាំតែស្លាកស្នាមរលុបអស់ដាន!»

«ចុះម៉ាស៊ីននិងរូបថតទាំងនេះ?!»

«អឺ គឺខ្ញុំយកតាមខ្លួនសិន! បើសិនបងរកខាង Steganographyបានខ្ញុំនឹងជួបគេភ្លាម ហើយអង្គុយមើលជាមួយគេ!»

គូសន្ទនារបស់នាងញញឹមស្រស់ៈ

«ចរិតការងាររបស់ធីតាប្រុងប្រយ័ត្នជាប៉ូលិសទៀតនៀក?»

នារីក្តាប់មាត់ឆ្លើយតបវិញដោយម៉ត់ចត់ៈ

«វាជារបស់ចុងក្រោយ ជាអនុស្សាវរីយ៍រវាងពូវុទ្ធីនឹងខ្ញុំ! »

គូសន្ទាងក់ក្បាលផ្ងក់ៗបង្ហាញទឹកមុខចូលរួមសោកស្តាយ។ ខាងស្រីវាចាបន្ថែមហាក់មិនទាន់អស់ចិត្តៈ

«ហើយ វាអាចជាតម្រុយនាំខ្ញុំទៅរកការពិតបានទាំងអស់ផងក៏មិនដឹង!»

គេនោះលូកដៃមករលាក់ជាមួយនាង។

«ជូនពរជោគជ័យធីតា!»

រតនគីរី និងភ្នំពេញមិនឆ្ងាយពីគ្នាដល់ថ្នាក់រំលងយប់ទេ។

ស្រីស្អាតបានមកដល់គោលដៅជាមួយសម្ពាយមួយ ដែលមានខោអាវពីរកំប្លេកូនសៀវភៅតូច សំណព្វ Laptop ម៉ាស៊ីនរូបថតចុងក្រោយរបស់ពូខ្លួន ព្រមជាមួយចម្ងល់ក៏ដូចជាសំណួររាប់ពាន់ឃ្លា ចច្រប់រសឹបពេញបេះដូង។

«ផ្ទះនោះចាស់យ៉ាងណារហូតដល់បង្កាន់ដៃអាចបែកបាក់សម្លាប់ម្ចាស់ផ្ទះបាន?»

នាងនិយាយទាំងខឹងផងបន្ទោសផង ប៉ុន្តែនាងនៅតែមានសំឡេងស្រទន់ល្មមឱ្យអធិការភារម្យមិនអាចបញ្ចេញភាពសោះអង្គើយបាន។

នាយប៉ូលិសវ័យ៣៥ឆ្នាំ រវៃភ្នែកសម្លឹងដងចិញ្ចើមក្រាស់កោងដូចធ្នូនៃនារីដ៏មានរូបឆោមលោមពណ៌។ នាងមានកែវភ្នែកមុតថ្លាតែស្លូតបូត បបូរមាត់ប៉ប្រិមតែវាងវៃ  រាងកាយទន់ល្វតតែរវាស។

«ធីតា! តាមថាយើងបានបិទចោលសំណុំរឿងនេះហើយ! ឧកញ៉ាវុទ្ធីស្លាប់គួរឱ្យសោកស្ដាយ តែគ្រប់យ៉ាងជាឧប្បត្តិហេតុ ប៉ូលិសបានពន្យល់នៅក្នុងរបាយការណ៍ដាក់ជូនអង្គចៅក្រម និងព្រះរាជអាជ្ញាហើយដែរ!»

នាងមិនរង្គោះរង្គើទឹកមុខទេ ដ្បិតអីនាងដឹងថាគេនឹងនិយាយបែបនេះ។ សម្ដីដែលព្រាងទុក ភាគច្រើនជាសំណួរ ដូច្នេះនាងមិនបង្អង់ឡើយ៖

«ហេតុអ្វីបង្កាន់ដៃនោះបាក់?»

នាងហាក់ដំឡើងលំដាប់សំឡេងតិចតួចតែនាយអធិការហាក់មិនខឹងតប។ បុរសនេះញញឹមតិចតួចតបទៅនឹងកែវភ្នែកមុតរបស់នាងជំនួសឱ្យចម្លើយ។ ដោយមិនអាចរង់ចាំបាន នារីបោះសំណួរបន្ថែមរ៉ាវៗ៖

«ផ្ទះនោះសង់មិនដល់២០ឆ្នាំផង វត្ថុធាតុដើមទាំងអស់ជាឈើប្រណីត លោកពូខ្ញុំទិញមកក្នុងតម្លៃជាងមួយលានកន្លះលុយអាមេរិក! គាត់បានដេគ័រ និងជួសជុលឡើងវិញដោយវិស្វករខ្លាំងៗនៃក្រុមហ៊ុនគុណភាពសំណង់ អង្គរបៀល! លោកអាចសិក្សាជាមួយពួកគេបាន ហេតុអ្វីលោកបិទសំណុំរឿងហើយព្រមជឿថា បង្កាន់ដៃនោះគ្មានមនុស្សមានចេតនាកាត់វាបំបាក់? ហេតុអ្វីលោកយល់ថា

ការស្លាប់នៃមនុស្សម្នាក់ដែលមិនសមហេតុផលជាឧប្បត្តិហេតុ? បើប៉ូលិសមូលដ្ឋានមិនមានលក្ខណៈសម្បត្តិបច្ចេកទេសគ្រប់គ្រាន់ក្នុងការស៊ើបក្តីនេះ ម្តេចមិនបន្តទៅដល់ដៃផ្នែកព្រហ្មទណ្ឌខេត្ត?»

«សូមបន្តិច! ជួយពន្យល់ផងបានទេ ពាក្យថា មិនមានលក្ខណៈសម្បត្តិបច្ចេកទេសគ្រប់គ្រាន់មិញនេះ?

អធិការភាវម្យស្សូរមកដោយទឹកមុខមាំ។ នាងដឹងថាសម្តីបានប៉ះទង្គិចផ្លូវចិត្តសមត្ថកិច្ចវ័យក្មេងដែលកំពុងមានវត្តមាននៅចំពោះមុខខ្លួន ប៉ុន្តែធីតាហាក់មិនស្តាយក្រោយដដែល ព្រោះនាងយល់ថា ពួកគេមានចេតនាបិទចោលសំណុំរឿងព្រោះមិនចង់លំបាក។

នាងក្រពាត់ដៃ ជាសញ្ញាបង្កើនភាពសៅហ្មងចេញមកបន្ថែម រហូតដល់ខាងបុរសមិនអាចនឹងបន្តការអត់ធន់។ គេនិយាយសង្កត់ពាក្យ៖

«នាងមាក់ងាយខ្ញុំ ខ្ញុំអាចអត់ទ្រាំ តែកុំបន្តអាកប្បកិរិយានេះប៉ះពាល់ដល់អង្គភាពទាំងមូល! ខ្ញុំដឹងថាធីតាជាបញ្ញាវន្ត ហើយនាងមានវិធីទប់ស្កាត់ភាពឆេវឆាវរបស់ខ្លួនឯងបាន»

«ខ្ញុំមិនឆេវឆាវទេ! អ្នកដែលឆេវឆាវនិងធ្វេសប្រហែស ប្រហែលអ្នកផ្សេង! ខ្ញុំនិយាយពីអ្នកដែល មិនអាចរកឃើញការពិតហើយប្រញាប់គេចវេះពីការងារ»

«សម្តីនាងចំណុចខ្លះ អាចធ្វើឱ្យនាងពិបាកដោះស្រាយចំពោះមុខច្បាប់បាន!»

គេព្រមានក្នុងសព្ទសំឡេងល្មមឮពីរនាក់។

បុរសនេះមានចេតនាការពារនាងពីការចាប់អារម្មណ៍របស់ប៉ូលិសដទៃ ដែលអើតកសម្លឹងមកពីក្រៅបន្ទប់។ ទីនេះជាការិយាល័យសាងអំពីឈើ ប្រសិនការសន្ទនាបន្ថែមសំឡេងធ្ងន់តែបន្តិច គ្រប់គ្នានឹងអាចឮអត្ថន័យនានាដែលនាងកំពុងចោទបន្ទុកលើសមត្ថកិច្ចមូលដ្ឋានបាន។

នាងក្រោកចោលកៅអីដោយទឹកមុខស្មើ។

កំហឹងក្នុងភ្នែក និងការអាក់អន់ចិត្តបានប្តូរសព្ទសំឡេងនាងឱ្យក្រងួរ។ ធីតាឆ្លើយឆ្លងប្រយោគចុងក្រោយ៖

«អ្នកប្តឹងគួរតែជាខ្ញុំ! ប៉ូលិសពួកលោកត្រូវតែធ្វើការស៊ើបអង្កេតឡើងវិញ! ខ្ញុំប្រាកដជារកបានភស្តុតាងដាក់បន្ទុក ហើយទីបញ្ចប់អង្គចៅក្រមនឹងឈរខាងខ្ញុំ!»

នាងទាញទ្វារកញ្ចក់ឈើ ដែលកាត់ផ្ដាច់បន្ទប់នេះចេញពីការចង់ដឹងឮនៃក្រុមប៉ូលិសស្រីប្រុសខាងក្រៅ ហើយចាកចេញវេរ៉ វ កាត់តាមបណ្ដាតុធ្វើការជាជួររបស់ពួកគេទាំងមិនខ្វីឱនគំនាប់គួរសមដាក់អ្នកណាដូចកាលពីទើបនឹងដើរចូលនោះទេ។

ស្នូរជើងមនុស្សរត់មកតាមពីក្រោយៈ

«ធីតាស្គាល់ផ្ទះឧកញ៉ាវុទ្ធីដែរ? ខ្ញុំអាចជូនទៅបាន!»

គឺសំឡេងអធិការភារម្យ។ បុរសនេះធ្វើឱ្យនាងខឹងឆ្អែត ថែមទាំងចេញមកតាមដើរតួជាមនុស្សចិត្តទូលាយនៅនឹងមុខកូនចៅពួកគេទៀត?

នាងឈប់ដំណើរ ហើយបែរក្រោយសម្លក់ម្ចាស់សំឡេងដោយកែវភ្នែកស្រទន់។ នាងស្រទន់យ៉ាងណាក៏នាយប៉ូលិសរកឃើញអត្ថន័យ «មិនខ្វីពឹង» នៅក្នុងក្រសែភ្នែកនោះដែរ។

គេសើចស្ងួតហើយឈរជ្រែងដៃពីចម្ងាយ ដោយមិនហ៊ានប្រដេញតាម។

ធីតាតាមបោះបង់ចោលការសម្លឹងព្រមានរបស់នាង រួចទើបបន្តចាកចេញ។ នៅលើកូនឡានពណ៌ក្រហមរាងខ្លីកន្ទុប និងមានដំបូលរាងមូល សឹងគួរឱ្យអស់សំណើចសម្រាប់អ្នកឃើញវាដំបូង នាងរោទ៍ម៉ាស៊ីន បន្ទាប់មករីយែរថយក្រោយលាន់រំពងផ្អើលពួកបក្សីបក្សាដែលកំពុងកៀងគូលើមែកព្រៃប្រឹក្ស។

«ប៉ូលិសអន់ៗ» នាងរអ៊ូម្នាក់ឯង។

**ជំពូកទី២**

## វិមានក្រអូប

ពិតជាចម្លែកណាស់ដែលផ្លូវចូលភូមិនេះជាងបីពាន់ម៉ែត្រ អមលម្អដោយរុក្ខាស្រងាត់ និងពពួកផ្កាព្រៃដ៏កម្រនៃដែនឰសានខ្មែរ។ គួរឱ្យស្ដាយដែលបុរសចំណាស់ដ៏ចាប់ចិត្តស្នេហាចំពោះធម្មជាតិបែរជាពេលនេះលែងនៅកំដរគេហដ្ឋានត្រកុំត្រកាលរបស់គាត់បាន។ នេះជាបំណងចុងក្រោយនៃជីវិតស្ងប់ស្ងាត់របស់គាត់ ហេតុអ្វីបានជាសំណាងអាក្រក់បានចូលមកបញ្ចប់គាត់ទាំងមិនអស់ចិត្ត?

ឡានឈប់ពីមុខរបស់ឈើរលោងស្តឹមស្តៃ ដែលមានតំកល់ស្លាក«ផ្ទះក្រអូប»។ នេះជាវិមានដែលគាត់តែងសរសេរមកអ្នកក្លួយស្រីជាមួយនឹងរូបថតច្រើនសន្លឹកជាបន្តបន្ទាប់។ នៅពេលឈានជើងចុះនាងទទួលអារម្មណ៍ដំបូងពីពិដោរដែលពិតជាសាកសមនឹងឈ្មោះរបស់ទីតាំង។

សព្វសត្វល្អិតនានាដែលពេញចិត្តស្រូបស្រង់គន្ធានៃបុស្បាធម្មជាតិមានចរាចរណ៍រវិច ក្បែរៗនាងមិនថាមេអំបៅឬឃ្មុំ។ ពួកគេមិនមានអារម្មណ៍ផ្អើលនឹងម្ចាស់កូនឡានទេ ប្រហែលមកពីក្លិនក្រអូបនៃបុប្ផានានាហាក់មានឥទ្ធិពលលើសលុបជាង។

នាងបិទទ្វារឡានទៅវិញគ្រាំ ព្រោះរវល់វក់នឹងសម្រស់នៃបរិយាកាស។ សន្ទឹកនេះប្រសិនបើផ្ទះខាងក្នុងនៅក្បែររបង ពិតជាមានអ្នកភ្ញាក់ផ្អើលមិនស្ទើរ តែមើលតាមសន្ទឹកស្លឹកឈើនិងកម្លាំងខ្យល់ នាងដឹងថាច្រើនម៉ែត្រពីទីនេះមិនមានស្រមោលមនុស្សទេ។

នាងសម្លឹងទៅទ្វារធំ ដែលគ្របដណ្តប់ដោយក្បាច់ចម្លាក់ផ្ចិតផ្ចង់ល្អវិចិត្រ ក្នុងចិត្តពិតជាលបលួចស្ញើចសរសើរកំពូលស្ថាបត្យកម្មដ៏កម្រ ស័ក្តិសមជាសម្បត្តិមានតម្លៃមហាសាល ទោះបីវាមានទីនៅចុងផុតនៃផ្លូវ ឆ្ងាយដាច់ភូមិករអ្នកស្រុកក្តី។

«ពូថាដីនេះពីបុរាណមក ធ្លាប់ជាប្រាសាទនៃស្តេចត្រាញ់ តែសំណង់បានរលាយបាត់ទៅ នៅសល់តែឈ្មោះ គ្មានសល់សូម្បីសំណៅអ្វីមួយជាតឹកតាង! ក្រោយៗមកជំនាន់បារាំងក៏មានមេស្រុកថៅហ្វាយខេត្តខ្លះបានមកតាំងទីលំនៅ! មកដល់ប៉ុលពតក៏រុះរើចោលអស់ទៀត ក្លាយជាកន្លែងចិញ្ចឹមសត្វ! ក្រោយរំដោះហើយ ម្ចាស់មុននោះគេសង់ផ្ទះនៅ ប៉ុន្តែកែកុនច្រើនយ៉ាងណាស់! ឆ្នាំ២០០២គេបានរុះរើធ្វើជាវិមានឈើបេង ដែលស្អាតផ្តាច់គេក្នុងប្រទេស អ្នកណាៗក៏ជញ្ជក់មាត់សរសើរ! បើមិនមានលក្ខខណ្ឌពិសេស ពូទិញមិនបានផ្ទះនេះទេធីតា!»

សម្តីពូនាងទាំងប៉ុន្មានមិនដែលរលុបបាត់ពីការចងចាំអ្វីម្តង ទោះបីនាងមិនដែលបានឆ្លៀតពេលមកអបអរផ្ទះរបស់គាត់ក៏ដោយ។

ដៃនារីរុញរបើកទ្វាររបង។

គ្មានអ្នកណាចាក់សោរប្រយ័ត្នប្រយែងអ្វីសោះ? ឬមួយនេះបង្ហាញពីទម្លាប់រស់នៅពោរពេញដោយសុវត្ថិភាពរបស់មនុស្សនៃតំបន់ព្រៃភ្នំបរិសុទ្ធ?

នាងនឹកដល់សំណួរចាស់របស់ខ្លួនឯង៖

«ពូរើទៅនៅឆ្ងាយផ្សារ ឆ្ងាយក្រុង ជំទាវមីងទម្លាប់បានដែរ?!»

«មឹងឯងរអ៊ូដែរពីដំបូង! តែក្រោយៗមកមានមិត្តភក្តិនិយមមកលេង ធ្វើ Partyច្រើន គាត់ក៏ដូចជាសប្បាយចិត្តដែលមានកម្មសិទ្ធិផ្ទះក្រអូបនេះ! មិត្តភក្តិសរសើរច្រើន គេចង់រកធ្វើផ្ទះតាមដែរ តែមិនងាយទេ!»

ផ្សែងស្រអាប់ពេលល្ងាច បង្ហើរចេញពីច្រករបៀងដែលមានពន្លឺពណ៌ក្រហមចុងក្រោយនៃព្រះទិនករហៀបអស្តង្គត។ ចិត្តនាងស្រស់ស្រាយនឹកឃើញដល់ពិធីជប់លៀងប្រកបដោយភ្លើងក្រហមនិងកម្រាលស ចូផ្កាចង្កោមក្រអូបដល់បេះដូង ក្រោមចំហាយអាកាសធាតុនៃព្រឹក្សព្រៃត្រជាក់ស្រទន់។

ស្នាមញញឹមបម្រុងនឹងឆាបឆេះកំដរបបូរមាត់ស្ងួតធេង បែរជារុះរោយព្រោះនាងនឹកដល់....

«ឧកញ៉ា ទេព វុទ្ធី ជាម្ចាស់អាជីវកម្មសណ្ឋាគារ និងResortដ៏ល្បីនៅកម្ពុជាត្រូវដួល ស្លាប់ភ្លាមៗនៅក្នុងការប្រារព្ធពិធីអបអរឆ្នាំថ្មីក្នុងផ្ទះធម្មជាតិតម្លៃជិត២លានដុល្លារអាមេរិករបស់គាត់! »

ធីតានឹកឃើញផង ជើងក៏ឈានចូលមួយៗទៅក្នុងបរិវេណភូមិគ្រឹះដែលអមលម្អដោយសព្វបក្សីបក្សាហើរច្រវាត់រកទ្រនំនេះផង។

«ប្រសិនឃាតករចង់បង្កើតកលល្បិចធ្វើឱ្យពូខ្ញុំធ្លាក់ស្លាប់កណ្ដាលចំណោមមនុស្សម្នា សាក្សីល្ងីល្ងើទាំងអស់ងាយណាស់ក្នុងការចូលស៊ីងគេ ដែលនាំគ្នាចង្អុលថា វាជាឧបទ្ទវហេតុ!»

នាងគិតម្នាក់ឯងទាំងសៅហ្មងរហូតពិបាកនឹងសប្បាយចិត្តបានទោះបីជាទិដ្ឋភាពទីនេះស្រស់បំព្រងកម្រិតណាក្តី។

ដោយសារគ្រប់យ៉ាងត្រជាក់ឡើងៗ នាងអោបដៃបង្កើនកម្តៅហើយជើងក៏បង្កើនល្បឿន។

ធម្មជាតិដ៏ត្រសុំ ជាសំណុំនៃផ្ទះចម្ការយ៉ាងរមនា បង្ហាញជ្រលងជងភ្នំនាជំរាលម្ខាងស្មើផ្ទាំងគំនូរប្រណីតៗ ពិបាកថាធ្វើចិត្តដូចមិនឃើញមិនលង់ តែយ៉ាងណានៅតែមិនបានប្តូរចិត្តនារីអ្នកកាសែតឱ្យសោមនស្សអ្វីថែមឡើងសូម្បីបន្តិចណាឡើយ ព្រោះកាន់តែឃើញវានាងកាន់តែស្រណោះម្ចាស់។

ស្រីតូចដើរកាត់ម្នាក់ឯងតាមកណ្ដាលសួនធម្មជាតិ ដែលខិតខំបញ្ចេញសម្រស់មុនពេលមេឃធ្លាក់ងងឹតដោយ ភ្នែកទាំងគូឆ្ពោះសម្លឹងទៅមុខរកមើលរូបរាងពិតធំចង្រ្កឹងនៃផ្ទះបេងខ្មៅមួយនេះ។ ពិតជាមិនធ្លាប់សូម្បីតែឃើញរូបភាពឱ្យបានម្តងណា កុំថាឡើយបានមកឃើញជាក់នឹងភ្នែកបែបនេះ។

អ្វីមួយកំពុងធ្វើចលនានៃខាងស្តាំដៃ។

នាងងាកភ្លាមហើយក្រឡេកមើលទៅគោលដៅ ស្របពេលសំឡេងមួយចាប់ផ្ដើមហើរមកតាមខ្យល់។

«អឺះៗ....»

នាងរត់ត្របាញ់ជើងទៅ ព្រោះនៅទីនោះមនុស្សម្នាក់កំពុងតែដេកដួលផ្កាប់មុខទៅលើដីជាមួយនឹងកាយវិការប្រវេប្រវាដូចកំពុងលង់ទឹក។

រទេះអង្គុយនៅក្បែរគាត់ បង្ហាញថាមនុស្សនេះទំនងជាពិការ ហើយបានជួបហេតុការណ៍បាត់ជំហររហូតដល់ដួលច្រងាប់ច្រងិលម្នាក់ឯង។

នៅប្រមាណជា១០ម៉ែត្រពីមុខនាង អ្នកផ្សេងម្នាក់បានរត់មកដល់មុន។

នោះជារូបរាងមនុស្សស្រីស៊ីវិល័យនិងមានសក់ពណ៌ហាយឡាយស្រស់ផូរផង់។ ដំណើរនាងល្វតល្វៃ ជាមួយអាវផ្កាវែង ពណ៌ផ្កាត្រគៀតដែលក្រាលគ្របសាកសមឥតទាស់លើស្បែកសហ្មត់។

វត្តមាននារីប្រផូរបានទុចដំណើរធីតាឱ្យបន្ថយល្បឿនជើង។

«អ្នកបងចរិយា!»

នាងហៅតិចៗដោយអំណរ។

នារីអាវស្វាយ លើកគ្រាហ៍បុរសចំណាស់ពីលើដីមកលើរទេះទាំងហាក់មិនដឹងវត្តមានធីតាឡើយ រហូតដល់នារីអ្នកកាសែតរត់មកជួយ ហើយលាន់មាត់ហៅឈ្មោះនាងផង ទើបងាកមកសម្លឹងភ្មៀរដោយភ្ញាក់ផ្អើល។

អ្នករងគ្រោះជាបុរសចំណាស់ម្នាក់ រាងស្គម ស្ដើងនិងមានទឹកមុខស្លូតបូត។ សុខភាពគាត់ទំនងជាខ្សោះខ្សោយ នេះបើតាមព្ទចង្វាក់ដង្ហើមនិងរបៀបអង្គុយរបស់គាត់។ ធីតានឹកឃើញដល់មនុស្សម្នាក់ភ្លាម។

ទោះបីជានាងនៅមិនទាន់បានហើបមាត់ហៅឈ្មោះគាត់នៅឡើយ តែនាងនឹកឃើញដល់សម្ដីលោកពូមុនស្លាប់៖

«ពូមានសំភិន! គេជាមិត្តដែលពូអាចនិយាយគ្រប់យ៉ាងជាមួយបាន!»

ស្ត្រីក្នុងរ៉ូបផ្កាកំពុងសម្លឹងមកធីតាហាក់ចម្លែកចិត្ត។

«ខ្ញុំធីតាណាបង!»

នាងណែនាំខ្លួនឯង។

ពិតណាស់ នារីនេះជាភរិយាស្រស់ស្អាតរបស់បងប្រុសជីដូនមួយខ្លួន។ ស្នាមញញឹមស្វាគមន៍តិចៗ និងសម្រស់ល្អគន់របស់នាង បានធ្វើឱ្យធីតាបង្វែរអារម្មណ៍ទៅជាស្រងេះស្រងោចនឹកដល់រឿងផ្សេងមួយទៀត។

«ឧត្តមបាត់ដំណឹង២អាទិត្យហើយ! ពូគេងមិនដែលលក់ទេធីតា! អ្វីៗដូចជាមិនទំនងកំពុងកើតឡើងមកលើគ្រួសារយើង! មានរឿងខ្លះពូគិតឃើញតែពិបាកបកស្រាយ! ពេលឯងប្រលងចប់ត្រូវមកភ្លាម ពូមានការចង់និយាយច្រើនណាស់! ពូគិតថា ក្មួយអាចជួយគិតពូបាន!»

សំឡេងគាត់ និងសព្ទព្រួយបារម្ភរបស់គាត់ បានកើតមានជាបន្តបន្ទាប់ចាប់ពីពេលដែលបងប្រុសជីដូនមួយនាង ដែលត្រូវជាកូនប្រុសតែមួយគត់របស់ពូនាងបានបាត់ខ្លួន។

ឧត្តមជាស្វាមីនារីរូបស្អាតនេះ បានបាត់ខ្លួនប្រមាណជិត ២ខែមុនពូនាងធ្លាក់ស្លាប់។

នារីស្រស់ផូរផង់ម្នាក់នេះ ជាជំទាវវ័យក្មេងឈ្មោះចរិយា ត្រូវជាភរិយាទើបនឹងរៀបការចូលគ្រួសារនេះបានប្រមាណជាងកន្លះឆ្នាំប៉ុណ្ណោះមុនស្វាមីបាត់ខ្លួន។

«ធីតា! មកដល់ពីអង្កាល់?»

ធីតាជួបជំទាវតូចនេះបានតែម្ដងគត់ គឺមុនមួយថ្ងៃនៃមង្គលការនាងជាមួយបងជីដូនមួយខ្លួន។ ជំទាវចរិយាមើលនាងមិនសូវចំណាំជារឿងធម្មតា។

បុរសចំណាស់ក្អកខេះៗ ខ្សោយៗហាក់កាត់ផ្ដាច់ការសន្ទនារបស់ពួកគេ។ ធីតាងាកទៅសម្លឹងគាត់បម្រុងនឹងហើយមាត់សួរថា «ជាលោកពូសំភិនមែនទេ?» ស្រាប់តែពពុះសស្គុះប្រជ្រៀតគ្នាហូរចេញមកបិទបាំងបបូរមាត់ជនចំណាស់។

បេះដូងនាងបុកភឹបដោយក្ដីតក់ស្លុត ស្របពេលនាងឮបងថ្លៃស្រីស្រែកប្រាប់៖

«ធីតា! ហៅពេទ្យសានមក! ពូសំភិនមិនស្រួលទេ!»

ធីតាស្លន់ស្លោ។ នាងក្រឡេកជុំវិញខ្លួនជាមួយសំណួរសម្ងាត់ក្នុងពេលតក់ក្រហល់៖

«ផ្ទះនេះគ្មានអ្នកបម្រើទេ? មនុស្សបាត់ទៅណាអស់ហើយ?!»

ជំទាវចរិយាសង្ងើញ៖

«ហៅពេទ្យសាន លឿនឡើង!»

«ពេទ្យ....ពេទ្យសា....សាន?»

ធីតាមិនធ្លាប់សូម្បីតែនឹងឮឈ្មោះនេះពីមុនមក។ បុរសចំណាស់ចាប់ផ្ដើមទ្រេតខ្លួនក្ដាប់ដៃដ៏រញ៉ីរញ៉ូររបស់គាត់ទាំងសង ហាក់កំពុងប្រឹងប្រែងទប់ទល់យ៉ាងលំបាកចំពោះស្ថានភាពរាងកាយ។ ភ្នែកគាត់បិទជ្រីវជ្រួញទាំងសង។

ធីតាឈានជើងថយក្រោយ តាមបញ្ជាបងថ្លៃរូបស្រស់ទាំងភ្នែកនៅកញ្ជ្រឹងក។

សូមរង់ចាំអានភាគទីពីរព្រឹកស្អែក